# ថ្នាំបង្ការរោគ គ្រុនផ្ដាសាយធំ 2009 H1N1

## ថ្នាំអសកម្ម
## *("ថ្នាំចាក់បង្ការរោគ")*

## អ្វីដែលលោកអ្នកត្រូវដឹង

មានសេចក្ដីថ្លែងព័ត៌មានថ្នាំបង្ការរោគ ជាច្រើន ជាភាសាអេស្ប៉ាញ៉ុល និងជាភាសាផ្សេងៗទៀត ។ សូមមើលនៅ www.immunize.org/vis ។

## 1 តើគ្រុនផ្ដាសាយធំ 2009 H1N1 ជាអ្វី?

គ្រុនផ្ដាសាយធំ 2009 H1N1 (ជួនកាលគេហៅថា Swine Flu) ជាភាសាខ្មែរហៅថា សូករោគគ្រុនផ្ដាសាយ ឬគ្រុនផ្ដាសាយជ្រូក បានបណ្ដាលដោយសារពូជមេរោគវីរុសថ្មីនៃគ្រុនផ្ដាសាយធំ ។ វាបានឆ្លងរាលដាលទៅប្រទេសជាច្រើន ។

ដូចគ្នានឹងមេរោគគ្រុនផ្ដាសាយធំផ្សេងៗទៀតដែរ រោគ 2009 H1N1 ឆ្លងរាលដាលពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត តាមរយៈការក្អក ការកណ្ដាស់ ហើយជួនកាលតាមរយៈការប៉ះនឹងវត្ថុអ្វីដែលមានប្រឡាក់មេរោគវីរុស ។

សញ្ញានៃរោគ 2009 H1N1 អាចរួមមាន :

- រហឹតរហៃ
- គ្រុនក្ដៅ
- ឈឺបំពង់ក
- ឈឺសាច់ដុំ
- ស្រៀវស្រាញ
- ក្អក
- កណ្ដាស់

មនុស្សខ្លះទៀតក៏អាចមានការរាករូស និងក្អួតចង្អោរផងដែរ ។

មនុស្សភាគច្រើនបានស្រួលខ្លួនឡើងវិញ ក្នុងពេលមួយអាទិត្យ ។ ប៉ុន្តែមនុស្សមួយចំនួន អាចមានរោគហើមសួត ឬមានជំងឺធ្ងន់ធ្ងរផ្សេងទៀត ។ រីឯមនុស្សខ្លះទៀត នឹងត្រូវចូលសំរាកនៅមន្ទីរពេទ្យ ហើយខ្លះទៀតអាចនឹងស្លាប់ ។

## 2 តើរោគ 2009 H1N1 ខុសគ្នាពីគ្រុនផ្ដាសាយធំ (តាមរដូវ) ធម្មតា ដោយរបៀបណា?

មេរោគវីរុសគ្រុនផ្ដាសាយធំតាមរដូវ ផ្លាស់ប្ដូរពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែវាមានភាពស្រដៀងនឹងគ្នាណាស់ ។

មនុស្សដែលធ្លាប់កើតមានគ្រុនផ្ដាសាយធំ នៅពេលកន្លងទៅ តាមធម្មតាមានភាពស៊ាំរោគខ្លះ ចំពោះនឹងមេរោគវីរុសគ្រុនផ្ដាសាយធំតាមរដូវ (ខ្លួនប្រាណរបស់គេបានកើនសមត្ថភាពខ្លះ ដើម្បីតតាំងនឹងមេរោគវីរុស) ។

មេរោគវីរុសគ្រុនផ្ដាសាយធំ 2009 H1N1 គឺជាពូជមេរោគវីរុសគ្រុនផ្ដាសាយធំថ្មីមួយ ។ វាមានភាពខុសគ្នាយ៉ាងខ្លាំង អំពីមេរោគវីរុសគ្រុនផ្ដាសាយធំតាមរដូវ ។

មនុស្សភាគច្រើនមានភាពស៊ាំរោគបន្តិចបន្តួច ឬគ្មានភាពស៊ាំរោគសោះ ចំពោះគ្រុនផ្ដាសាយធំ 2009 H1N1 (ខ្លួនប្រាណរបស់គេមិនបានប្រុងប្រៀបដើម្បីតតាំងនឹងមេរោគវីរុសឡើយ) ។

## 3 ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ 2009 H1N1

សព្វថ្ងៃនេះមានថ្នាំបង្ការរោគ ដើម្បីការពារប្រឆាំងនឹងគ្រុនផ្ដាសាយធំ 2009 H1N1 ។

- ថ្នាំបង្ការរោគទាំងនេះ គឺបានផលិតឡើងដូចគ្នានឹងថ្នាំបង្ការរោគគ្រុន ផ្ដាសាយធំតាមរដូវដែរ ។
- ថ្នាំទាំងនេះត្រូវបានរំពឹងថាមានសុវត្ថិភាព និងមានប្រសិទ្ធិភាពដូចគ្នានឹងថ្នាំបង្ការរោគគ្រុនផ្ដាសាយធំតាមរដូវដែរ ។
- ថ្នាំទាំងនេះនឹងមិនការពារជំងឺ "ដូចគ្រុនផ្ដាសាយធំ" ដែលបានបណ្ដាលមកពីមេរោគវីរុសផ្សេងៗទៀតឡើយ ។
- ថ្នាំទាំងនេះនឹងមិនការពារគ្រុនផ្ដាសាយធំតាមរដូវទេ ។ ***បើអ្នកចង់ការពារកុំឲ្យឆ្លងគ្រុនផ្ដាសាយធំតាមរដូវ អ្នកគួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំតាមរដូវផងដែរ ។***

ថ្នាំបង្ការរោគ**អសកម្ម** (ថ្នាំបង្ការរោគដែលបានសំឡាប់មេរោគវីរុសនៅក្នុងវា) ត្រូវបានចាក់ចូលទៅក្នុងសាច់ដុំ ដូចគ្នានឹងការចាក់ថ្នាំការពារគ្រុនផ្ដាសាយធំ ជាប្រចាំឆ្នាំដែរ ។ **សន្លឹកនេះរៀបរាប់ អំពីថ្នាំបង្ការរោគអសកម្ម ។**

សព្វថ្ងៃនេះក៏មានថ្នាំបង្ការរោគ**រស់ បាញ់តាមច្រមុះ** (ថ្នាំបង្ការរោគបាញ់ចូលតាមច្រមុះ) ផងដែរ ។ ព័ត៌មានអំពីថ្នាំនេះ មានរៀបរាប់នៅសន្លឹកមួយដោយឡែកទៀត ។

ថ្នាំបង្ការរោគអសកម្ម 2009 H1N1 មួយចំនួន មានសារធាតុរក្សាទុកមួយហៅថា ធីម៉ីរ៉ូសាល់ (thimerosal) ដើម្បីរក្សាវាកុំឲ្យមានមេរោគ ។ មនុស្សខ្លះគេក៏បានឲ្យយោបល់ថា សារធាតុធីម៉ីរ៉ូសាល់ អាចនឹងជាប់ទាក់ទងចំពោះរោគមនោវិកលតែ គឺជំងឺរវើរវាយ និងភាន់វិញ្ញាណក្នុងកុមារវ័យ ។ នៅក្នុងឆ្នាំ 2004 ពួកអ្នកជំនាញមួយក្រុម នៃវិទ្យាស្ថានពេទ្យ (Institute of Medicine) បានពិនិត្យមើលឡើងវិញ អំពីការសិក្សាជាច្រើន ដោយរកមើលទៅលើទ្រឹស្ដីនេះ ហើយពុំបានរកឃើញទំនាក់ទំនងអ្វី រវាងនឹងសារធាតុធីម៉ីរ៉ូសាល់ និងរោគមនោវិកលតឡើយ ។ ចាប់តាំងពីពេលនោះមក ការសិក្សាបន្ថែមក៏បានធ្វើសេចក្ដីសន្និដ្ឋានដូចគ្នា ។

## 4 តើអ្នកណាខ្លះ គួរតែទទួលថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ 2009 H1N1 និងនៅពេលណា?

### អ្នកណាខ្លះ

ក្រុមមនុស្សដែលបានឲ្យយោបល់ ដើម្បីទទួលថ្នាំបង្ការរោគ 2009 H1N1 ជាដំបូងគេគឺ :

- ស្ត្រីមានផ្ទៃពោះ
- មនុស្សរស់នៅនៅជាមួយ ឬមើលថែទាំទារក អាយុក្មេងជាង 6 ខែ
- អ្នកថែរក្សាសុខភាព និងបុគ្គលិកពេទ្យផ្នែកសង្គ្រោះភាពអាសន្ន
- មនុស្សណាម្នាក់ មានអាយុចាប់តាំងពីអាយុ 6 ខែ រហូតដល់អាយុ 24 ឆ្នាំ
- មនុស្សណាម្នាក់ មានអាយុចាប់តាំងពីអាយុ 25 ឆ្នាំ រហូតដល់អាយុ 64 ឆ្នាំ ដែលមានលក្ខណៈរោគារ៉ាំរ៉ៃ ឬខ្សោយប្រព័ន្ធស៊ាំរោគ

នៅពេលណាមានថ្នាំបង្ការរោគថែមទៀត ក្រុមទាំងនេះក៏គួរតែបានចាក់ថ្នាំបង្ការរោគដែរ :

- មនុស្សមានសុខភាពល្អ អាយុ 25 ឆ្នាំ រហូតដល់ 64 ឆ្នាំ
- មនុស្សចាស់អាយុ 65 ឆ្នាំ និងចាស់ជាង

រដ្ឋាភិបាលសហព័ន្ធកំពុងតែផ្ដល់ថ្នាំបង្ការរោគនេះ សំរាប់មនុស្សព្រមទទួលដោយស្ម័គ្រចិត្ត ។ តែជាយ៉ាងណាមិញ ច្បាប់រដ្ឋ ឬក្រុមហ៊ុនការងារ អាចនឹងដំរូវឲ្យមានការចាក់ថ្នាំបង្ការរោគ សំរាប់មនុស្សមួយចំនួន ។

### ពេលវេលា

ត្រូវចាក់ថ្នាំបង្ការរោគ យ៉ាងឆាប់រហ័សនៅពេលមានថ្នាំបង្ការរោគ ។

ក្មេងៗមានអាយុរហូតដល់ទៅ 9 ឆ្នាំ គួរតែទទួលថ្នាំបង្ការរោគ**ពីរដូស្ស** គឺពីរករិតចន្លោះគ្នាប្រហែលជាពីរខែ ។ ក្មេងៗដែលចាស់ជាង និងមនុស្សចាស់ ត្រូវការតែមួយដូស្សប៉ុណ្ណោះ ។

## 5 មនុស្សខ្លះមិនគួរគប្បីទទួលថ្នាំបង្ការរោគទេ ឬគួររង់ចាំ

**បើអ្នកមានប្រតិកម្មធ្ងន់ធ្ងរ (ការគំរាមកំហែងជីវិត) ដោយមានប្រតិកម្មទឹងពងសត្វ ឬសារធាតុអ្វីផ្សេងទៀតនៅក្នុងថ្នាំបង្ការរោគ** អ្នកមិនត្រូវទទួលថ្នាំ 2009 H1N1 ទេ ។ *បើអ្នកមានប្រតិកម្មធ្ងន់ធ្ងរអ្វីមួយ ត្រូវប្រាប់មនុស្សដែលផ្តល់ថ្នាំបង្ការរោគឲ្យអ្នក ។*

ក៏ត្រូវប្រាប់គេដែរ បើអ្នកធ្លាប់មាន :

- ប្រតិកម្មដែលគំរាមកំហែងជីវិត បន្ទាប់ពីទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវមួយដូស្ស គឺមួយករិត
- រោគ Guillain-Barré Syndrome (ជារោគកំរើកឈ្លើចដ៏ធ្ងន់ធ្ងរ ដែលក៏ហៅកាត់ថា GBS ដែរ) ។

ថ្នាំទាំងនេះមិនអាចនឹងជាមូលហេតុ ដើម្បីជៀសវាងថ្នាំបង្ការរោគទេ ប៉ុន្តែបុគ្គលិកពេទ្យអាចជួយអ្នកសំរេចបាន ។

បើអ្នកមានជំងឺធុនស្រាល ឬធ្ងន់ធ្ងរ យើងឲ្យឱវាទអ្នកឲ្យរង់ចាំទំរាំអ្នកបានធូរស្បើយសិន មុននឹងទទួលថ្នាំបង្ការរោគ ។ បើអ្នកមានគ្រុនផ្តាសាយធុនស្រាល ឬមានជំងឺផ្សេងៗទៀត តាមធម្មតាមិនបាច់រង់ចាំទេ ។

ស្ត្រីមានផ្ទៃពោះ ឬស្ត្រីបំបៅដោះកូន អាចទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំ 2009 H1N1 អសកម្មបាន ។

ថ្នាំបង្ការរោគ 2009 H1N1 អសកម្ម អាចនឹងបានឲ្យនៅ ពេលព្រមគ្នា ដូចថ្នាំបង្ការរោគផ្សេងៗទៀតដែរ រួមទាំងថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវផង ។

## 6 តើមានគ្រោះថ្នាក់អ្វីខ្លះ បណ្តាលមកពីថ្នាំ 2009 H1N1?

ថ្នាំបង្ការរោគ ក៏ដូចនឹងថ្នាំផ្សេងៗទៀតដែរ ដែលអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាមានប្រតិកម្មខ្លាំង ជាដើម ។ ប៉ុន្តែភាពគ្រោះថ្នាក់នៃថ្នាំបង្ការរោគណាមួយ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់ គឺមានតិចតួចពេកណាស់ ។

មេរោគវីរុសនៅក្នុងថ្នាំបង្ការរោគ 2009 H1N1 អសកម្ម ត្រូវបានសំឡាប់ហើយ ដូច្នេះហើយ អ្នកមិនអាចកើតគ្រុនផ្តាសាយធំ អំពីថ្នាំបង្ការរោគឡើយ ។

ភាពគ្រោះថ្នាក់បណ្តាលមកពីថ្នាំបង្ការរោគ 2009 H1N1 អសកម្ម គឺស្រដៀងគ្នានឹងថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម តាមរដូវដែរ :

**បញ្ហាស្រាលៗ :**

- ឈឺសង្កៀរ ឡើងក្រហម ឈឺយ៉ាងខ្លាំង ឬហើមនៅត្រង់កន្លែងមុខម្ជុល
- សន្លប់ស្មារតី (ភាគច្រើនក្នុងពួកជំទង់ៗ)
- ឈឺក្បាល ឈឺសាច់ដុំ
- គ្រុនក្តៅ
- រមួលពោះ

បើមានបញ្ហាទាំងនេះកើតឡើង តាមធម្មតាវាចាប់ផ្តើមភ្លាមបន្ទាប់ពីបានចាក់ថ្នាំ ហើយមានរយៈពេលពី 1-2 ថ្ងៃ ។

**បញ្ហាធ្ងន់ធ្ងរ :**

- ប្រតិកម្មដែលគំរាមកំហែងជីវិត ទៅនឹងថ្នាំបង្ការរោគ គឺកម្រមានណាស់ ។ បើសិនជាវាកើតឡើង តាមធម្មតាវាមានក្នុងពេលពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីបានទទួលថ្នាំបង្ការរោគ ។
- នៅក្នុងឆ្នាំ 1976 ប្រភេទដំបូងនៃថ្នាំបង្ការសូករោគផ្តាសាយ (swine flu ឬគ្រុនផ្តាសាយជ្រូក) បានជាប់ទាក់ទងជាមួយនឹងករណីនៃរោគ Guillain-Barré Syndrome (GBS) ។ ចាប់តាំងពីពេលនោះមក ថ្នាំបង្ការរោគគ្រុនផ្តាសាយធំមិនបានជាប់ទាក់ទងគ្នាច្បាស់លាស់ ទៅនឹងរោគ GBS ទេ ។

## 7 ចុះបើសិនជាមានប្រតិកម្មធ្ងន់ធ្ងរវិញនោះ?

**តើខ្ញុំគួរតែឃ្លាំរកមើលអ្វី?**

លក្ខណៈចំឡែកអ្វីមួយខុសពីធម្មតា ដូចជាគ្រុនក្តៅខ្លាំង ឬអាកប្បកិរិយាប្រែប្រួល ។ សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ អាចរួមមាន ការពិបាកដកដង្ហើម ស្អកសំឡេង ឬការតឹងដង្ហើម មានកន្ទួលលើស្បែក ស្លេកស្លាំង ខ្សោយកំឡាំង ចង្វាក់បេះដូងដើរញាប់ៗ ឬវិលមុខ ។

**តើខ្ញុំត្រូវធ្វើយ៉ាងណា?**

- **ទូរស័ព្ទ**ទៅគ្រូពេទ្យ ឬយកមនុស្សនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- **ប្រាប់**គ្រូពេទ្យ អំពីអ្វីដែលបានកើតឡើង បានកើតឡើងនៅថ្ងៃខែឆ្នាំណា និងវេលាម៉ោងប៉ុន្មាន ហើយបានទទួលថ្នាំបង្ការរោគពីពេលណា ។
- **ស្នើ**គ្រូពេទ្យរបស់អ្នក ឲ្យរាយការណ៍អំពីប្រតិកម្ម ដោយបំពេញក្រដាសប្រព័ន្ធរបាយការណ៍ព្រឹត្តិការណ៍ប្រតិកម្មថ្នាំបង្ការរោគ (Vaccine Adverse Event Reporting System - VAERS) ។ ឬអ្នកអាចបំពេញសេចក្តីរាយការណ៍នេះ តាមវ៉ិបសៃត៍របស់ VAERS នៅឯ **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅលេខ **1-800-822-7967** ។

*VAERS មិនផ្តល់ឱវាទផ្នែកសុខភាពឡើយ ។*

## 8 ការធានារ៉ាប់រងគ្រោះថ្នាក់ បណ្តាលមកពីថ្នាំបង្ការរោគ

បើរូបអ្នក ឬកូនរបស់អ្នក មានប្រតិកម្មទៅនឹងថ្នាំបង្ការរោគ សមត្ថភាពរបស់អ្នកដើម្បីប្តឹងផ្តល់ គឺបានកំរិតដោយច្បាប់ ។

តែជាយ៉ាងណាមិញ កម្មវិធីនៃរដ្ឋបាលសហព័ន្ធ បានបង្កើតឡើងដើម្បីជួយបង់ថ្លៃការថែទាំរោគា និងការចំណាយផ្សេងៗទៀត សំរាប់មនុស្សមួយចំនួន ដែលមានប្រតិកម្មធ្ងន់ធ្ងរ ទៅនឹងថ្នាំបង្ការរោគនេះ ។ សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមទូរស័ព្ទលេខ **1-888-275-4772** ឬមើលវ៉ិបសៃត៍របស់កម្មវិធី នៅឯ : **www.hrsa.gov/countermeasurescomp/default.htm** ។

## 9 តើខ្ញុំធ្វើយ៉ាងណា ឲ្យបានយល់ដឹងបន្ថែមទៀត?

- សាកសួរគ្រូពេទ្យរបស់អ្នក ។ គេអាចផ្តល់ពត៌មានដែលមានភ្ជាប់ជាមួយប្រអប់ថ្នាំ ឬផ្តល់យោបល់អំពីប្រភពព័ត៌មានផ្សេងៗទៀត ។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំតំបន់ ឬក្រសួងសុខាភិបាលរដ្ឋ ។
- សូមទាក់ទងទៅមណ្ឌលសំរាប់ទប់ស្កាត់ និងបង្ការជំងឺ (Centers for Disease Control and Prevention - CDC) :
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - សូមមើលវ៉ិបសៃត៍របស់ CDC នៅ **www.cdc.gov/h1n1flu** ឬ **www.cdc.gov/flu**
- សូមមើលវ៉ិបសៃត៍នៅឯ **www. flu.gov**

DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement 42 U.S.C. §300aa-26
2009 H1N1 Inactivated Influenza Vaccine IMM-980CA – Cambodian 10/2/09
Translated by Transcend Translations, Davis, CA www.transcend.net